ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបអនុប្រធានក្រុមហ៊ុន **Qata Al Meezan Holding Group**



នៅរសៀលថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបលោក **Hamad Mhammed Al Abdan** អនុប្រធានក្រុមហ៊ុន **Qata Al Meezan Holding Group** នៃប្រទេស ហ្កាតា និងសហការី ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។

លោក **Hamad Mhammed Al Abdan** អនុប្រធានក្រុមហ៊ុន **Qata Al Meezan Holding Group** នៃប្រទេស ហ្កាតា បានវាយតម្លៃខ្ពស់ចំពោះភាពរីកចម្រើនដ៏ឆាប់រហ័សរបស់កម្ពុជា ហើយបង្ហាញនូវការចាប់អារម្មណ៍នូវសក្តានុពលសេដ្ឋកិច្ចនៅទីនេះ ។ ក្នុងនោះចង់សិក្សាស្វែងយល់ពីវិស័យវិនិយោគមួយចំនួន មានដូចជា៖ ផលិតផលឈើខ្លឹមច័ន្ទ–ការនាំចេញអង្ករ–ផលិតផលកសិ–ឧស្សាហកម្ម –វិនិយោគផ្នែកសណ្ឋាគារ–លំនៅដ្ឋាន និងផ្នែកទូរគមនាគមន៍ ។ ហើយ នៅថ្ងៃបន្ទាប់ប្រតិភូរបស់លោក នឹងអញ្ជើញទៅទស្សនៈកិច្ចស្វែងយល់ នៅខេត្តព្រះសីហនុ ។



មានប្រសាសន៍ឆ្លើយតប ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងចាត់ទុកការចង់សិក្សាស្វែងយល់នៃវិស័យវិនិយោគខាងលើ មានលក្ខណៈប្រាកដនិយម និងអំណោយផលច្រើន ។ ឯកឧត្តម បានបញ្ជាក់ថា៖កម្ពុជាមានប្រភេទអង្ករច្រើនសណ្ឋាន ជាពិសេសអង្ករផ្កាម្លិះ បានជាប់លេខ០១ ជាអង្ករឆ្ងាញ់ជាងគេលើពិភពលោក ហើយកម្ពុជា ក៏មានប្រភេទចុងអង្ករ រឺអង្ករបាក់ ដែលទីផ្សារពិភពអារ៉ាប់ត្រូវការផងដែរ ។ បច្ចុប្បន្នកម្ពុជាក៏កំពុងពិនិត្យលទ្ធភាពផលិតម្ហូបហាឡាល (Halal) សម្រាប់ផ្គត់ផ្គង់អ្នកកាន់សាសនាអ៊ីស្លាមដែលមានចំនួនដ៏ច្រើនលើពិភពលោក ។ ទាក់ទងនិងផលិតផលកសិ–ឧស្សាហកម្ម ឯកឧត្តមបានបញ្ជាក់ថា៖កម្ពុជាមានប្រភេទផលិតផលដែលមានសក្តានុពលនាំចេញ មានដូចជា៖ល្ង–ពោត–សណ្តែក ស្វាយ និងកៅស៊ូ ជាដើម ។ ដោយឡែក ទាក់ទងនិងផលិតផលឈើខ្លឹមច័ន្ទ គឺអាចទាក់ទងទិញតាមផ្ទះ រឺក្រុមហ៊ុនឯកជនបាន ។ ចំពោះការវិនិយោគលើវិស័យទូរគមនាគមន៍ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា៖ កម្ពុជាមានភាពរីកចម្រើនណាស់លើវិស័យនេះ គឺ ប្រជាជនប្រមាណ១៥លាននាក់ គាត់ប្រើ ស៊ីមកាតដាក់បញ្ចូលក្នុងទូរស័ព្ទ ប្រមាណជាង ២០ លាន ។ ទាក់ទង និងដំណើរទស្សនៈកិច្ចស្វែងយល់ នៅខេត្តព្រះសីហនុ ដែលជាខេត្តមាត់សមុទ្រ មានសក្តានុពលខ្ពស់ផ្នែកទេសចរណ៍របស់កម្ពុជា ឯកឧត្តម បានជម្រាបថា៖ក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២៥ ខេត្តព្រះសីហនុ ត្រូវបានចាត់ទុកជាខេត្តគ្របដណ្តប់ដោយតំបន់សេដ្ឋកិច្ចពិសេសមានលក្ខណៈពហុបំណង ព្រោះជាខេត្ត មានភូមិសាស្ត្រនៅចំកណ្តាលអាស៊ាន ងាយស្រួលដឹកជញ្ជូន និងធ្វើពាណិជ្ជកម្មឆ្លងកាត់ ។ ឯកឧត្តមបញ្ជាក់ថា៖សមស្របណាស់ ក្នុងការវិនិយោគ ផ្នែករោងចក្រ–សណ្ឋាគារ–លំនៅដ្ឋាន–និងកំពង់ផែទឹកជ្រៅ ។



ឆ្លៀតឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានលើកឡើងពីសក្តានុពល និងគោលនយោបាយលើកទឹកចិត្តផ្នែកវិនិយោគរបស់កម្ពុជា ជាពិសេសកម្ពុជាទទួលបានលក្ខណៈពិសេសផ្នែកពាណិជ្ជកម្ម ក្នុងការនាំចេញ ដោយរួចពន្ធ និងមិនជាប់កូតា ទៅកាន់ប្រទេសអភិវឌ្ឍន៍ និងប្រទេសដៃគូជាច្រើន ។ ពិសេសទៅទៀត នៅចុងឆ្នាំ២០១៥ នេះ ប្រទេសអាស៊ានទាំង១០ នឹងបង្កើតបាននូវសហគមន៍សេដ្ឋកិច្ចអាស៊ានមួយ ដែលមានការបើកទូលាយយ៉ាងខ្លាំងផ្នែកសេដ្ឋកិច្ច ។ ក្នុងនោះគោលដៅរបស់អាស៊ាន គឺការធ្វើពាណិជ្ជកម្មដោះដូរជាមួយប្រទេសនៅមជ្ឈឹមបូព៌ាផងដែរ ។

